## ការបង្កើតកណ្ដៀរ និងសត្វល្អិតជាចំណីមាន់

សត្វមាន់-ទាដែលកសិករចិញ្ចឹមនៅតាមផ្ទះជាទូទៅ ច្រើនតែចិញ្ចឹមលែង អោយវាដើរកកាយស្វែងរកចំណី ដោយខ្លួនឯងតាមលក្ខណៈធម្មជាតិ។ វិធីម្យ៉ាងដែលអាច បង្កើតអាហារពីធម្មជាតិ គឺការបង្កើតសត្វល្អិត ។ ព្រោះ សត្វល្អិត គឺជាអាហារដែលមានគុណភាពខ្ពស់ សំរាប់ បង្កើនការលូតលាស់ដល់សត្វមាន់ជាពិសេសគឺកូនមាន់។

## ការរៀបចំរណ្ដៅសំរាប់បង្កើតសត្វល្អិត



ទីតាំងសំរាប់ជីករណ្ដៅត្រូវជីកនៅក្រោយផ្ទះ ឬនៅ ក្បែររបងផ្ទះ។ រណ្ដៅសត្វល្អិតមួយត្រូវមានប្រវែង :

- ⁕ បណ្ដោយ ១ម៉ែត្រ
- ⁕ ទទឹង ១ម៉ែត្រ និង ជំរៅ ០.៣ម៉ែត្រ ។

ត្រូវជីករណ្ដៅយ៉ាងតិចអោយបានចំនួន ២ ទៅ



⁕ នៅបាតរណ្ដៅ ត្រូវដាក់ជីលាមកគោស្ងួតដោយ បរិមាណសមល្មម ។

⁕ រៀបកំណាត់ឈើស្ងួត ឬ ពុក ដាក់ឆ្លាស់ជាមួយជី លាមកគោស្ងួត២-៣ស្រទាប់ ។



ការដាក់កំទេចកំទីនិងស្លឹកឈើស្ងួត ពីលើគំនរឈើ





※ សកម្មភាពបន្ទាប់ស្រោចទឹកអោយជោគលើរណ្តៅសត្វល្អិត ។

※ យកបាវចាស់ៗគ្របពីលើ ហើយយកឈើសង្កត់ដើម្បីការពារមាន់កកាយ ។

※ ទុកចោលប្រមាណ ៣-៧ ថ្ងៃ សត្វល្អិត នឹងកកើតឡើងក្នុងគំនរឈើនោះ ។

※ បន្ទាប់មកបើកគំរប និងគំនរឈើនោះ រួចអោយមាន់និងកូនមាន់មកកកាយស៊ីសត្វល្អិតដែលកើតមាននៅក្នុងគំនរ ។

※ នៅពេលមាន់ស៊ីអស់យើងអាចរៀបចំរណ្តៅនោះសាជាថ្មីដូចដើមវិញ ។



※ ប្រសិនបើយើងអាចរៀបចំរណ្តៅអោយបាន ២-៣ រណ្តៅហើយបើកអោយមាន់ស៊ីសាចុះសាឡើង ជារឿយៗ នោះយើងអាចសន្សំសំចៃថ្លៃចំណីសំរាប់មាន់បានមួយកំរិត និងជួយអោយសត្វមាន់ មានការ ធំធាត់យ៉ាងឆាប់រហ័ស។

**រៀបចំដោយ**

**នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម**
**នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**ឧបត្ថម្ភថវិកាដោយអង្គការស្បៀង និងកសិកម្ម**
**នៃសហប្រជាជាតិ (FAO)**
**ទំនាក់ទំនងទូរស័ព្ទ : ០២៣ ២១៥ ៨១៩**

# ការបង្កើតកណ្តៀរ និង សត្វល្អិតជាចំណីមាន់



កម្មវិធីសម្រាប់សន្តិសុខស្បៀង និង កាត់បន្ថយភាពក្រីក្រ (FSPR)
ឆ្នាំ ២០០៨